ញ៉ុក . ថែម

# មហាវេស្សន្តរជាតក



## ភាគទី ៤

ផ្សាយឡើងវិញ "មជ្ឈមណ្ឌលវប្បធម៌"
រក្សាសិទ្ធិគ្រប់យ៉ាង
ព.ស ២៥៤៦ គ.ស ២០០២

# មហាវេស្សន្តរជាតក

## សម្រាប់ទេសន៍

## ទី ៩

# កណ្ឌវនប្បវេសន៍

ប្រដាប់ដោយគាថា ៥៧

បោះពុម្ពលើកទី ២
ចំនួន ១.០០០ ច្បាប់

## ភ្នំពេញ

ការផ្សាយចេញរបស់សាសនាបណ្ឌិត្យ
ព.ស ២៥០៩

Websites: WatKhemaraRatanaram.org or WatKhmers.org

# មហាវេស្សន្តរជាតក

## ទី ៩

## កណ្ឌវនប្បវេសន៍

នមោតស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

តេ បដិបថេ អាគច្ឆន្តេ មនុស្សេ ទិស្វា កុហឹ វង្កតបព្វតោតិ បុច្ឆន្តិ ។

បពិត្រអើយ រីក្សត្រទាំង ៩ អង្គ ស្តេចលីលាយាត្រាទៅ ប្រទះនឹងអស់មហាជនផងទាំងឡាយ ដើរទៅដើរមក ទើបព្រះអង្គ ដណ្តឹងសួររកផ្លូវទៅកាន់គិរីវង្កតបពិតថាដូច្នេះ ‹‹ម្នាលអ្នកទាំងឡាយ អើយ ផ្លូវទៅកាន់ភ្នំគិរីវង្កតបពិតនោះនៅឯណា›› ។ ទូរេតិ វទន្តិ ។ រីអស់មហាជនផងទាំងឡាយ ស្តាប់ព្រះបន្ទូលព្រះមហាក្សត្រហើយ មុខគួរអាសូរករុណា ក្រាបទូលថាដូច្នេះ ‹‹បពិត្រក្សត្រថ្លៃប្រសើរអើយ រីផ្លូវទៅកាន់ភ្នំគិរីវង្កតបពិតនោះឆ្ងាយក្តាត់ហោង ។ តេន វុត្តំ ហេតុ នេះហោង ព្រះអង្គមានព្រះបន្ទូលនឹងព្រះមហាសារីបុត្តត្ថេរ សូត្រជា បាទព្រះគាថាដូច្នេះ ៖

Websites: WatKhemaraRatanaram.org or WatKhmers.org

យទិ កោចិ មនុជា ឯន្តិ   អនុមគ្គេ បដិបថេ
មគ្គន្តេ បដិបុច្ឆាម   កុហឹ វង្កតបព្វតោ ។
តេ តត្ថ អម្ហេ បស្សិត្វា   កលូនំ បរិទេវយុំ
ទុក្ខន្តេ បដិវេទេន្តិ   ទូរេ វង្កតបព្វតោតិ ។

ភោ សារីបុត្ត ហៃសារីបុត្តអើយ រីកាលតថាគតនៅជាព្រះវេស្សន្តរ ស្ដេចចេញទៅពីជេតុត្តរនគរនោះ ប្រទះនឹងមហាជន ផងទាំងឡាយដើរទៅដើរមក ដោយនូវផ្លូវជើងតូចជើងធំច្រឡំច្រើនក្ដី ក៏ព្រះអង្គមានព្រះបន្ទូលដណ្ដឹងសួរថា «ម្នាលអ្នកទាំងឡាយអើយ ផ្លូវឯណាទៅកាន់ភ្នំវង្កតបពិតនោះ ចូរអ្នកទាំងឡាយប្រាប់អញផង» ។ រីអស់មហាជនផងទាំងឡាយ ស្ដាប់ព្រះបន្ទូលព្រះមហាក្សត្រហើយ ក៏នាំគ្នាទូញយំអាសូរករុណាព្រះបរមពោធិសត្វ ហើយទូលនូវពាក្យដូច្នោះថា «បពិត្រក្សត្រថ្លៃប្រសើរអើយ រីផ្លូវទៅកាន់ភ្នំគិរីវង្កតបពិតនោះឆ្ងាយក្ដាត់ពេកហោង» ។

មគ្គស្ស ឧភោសុ បស្សេសុ ពិជផលជាវិនោ រុក្ខា និស្វា ធារកា ភេទន្តិ ។ កាលស្ដេចលីលាទៅនោះ សឹងដ៏មានឈើ

ទាំងសងខាងផ្លូវនោះច្រើន ដ៏ទ្រង់នូវផ្លែផ្កាវន្ទាលច្រាលផ្សេងៗ ព្រះរាជកុមារទាំងពីរយល់ហើយ អង្វរព្រះបិតាឲ្យបេះឲ្យព្ធដ៏កាលនោះ ។ ហេតុតែអានុភាពនៃព្រះមហាក្សត្រនោះមិញ រីឈើផងទាំងឡាយដ៏ខ្ពស់ក្រៃ ដៃដំរីនឹងឈោងមិនដល់ ហេតុតែព្រះបារមីព្រះពោធិសត្វ រីឈើទាំងនោះ ក៏ឱនលំទោនមកទៀបព្រះហស្ត ហើយស្តេចបេះឲ្យព្រះរាជបុត្រទាំងពីរបរិភោគ ព្ធដ៏កាលនោះហោង ។ ព្រះនាងមទ្រីយល់ជាអស្ចារ្យប្រាកដដូច្នោះ ព្រះនាងក៏សរសើរព្រះបារមីព្រះពោធិសត្វ ។ តេន វុត្តំ ហេតុនោះហោង ព្រះអង្គមានព្រះបន្ទូលនឹងព្រះមហាសារីបុត្តត្ថេរ សូត្រជាបាទព្រះគាថាដូច្នេះ ៖

| | |
|---|---|
| យទិ បស្សន្តិ បវនេ | ទារកា ផលិតេ ទុមេ |
| តេសំ ផលានំ ហេតុម្ហិ | ឧបរោទន្តិ ទារកា ។ |
| រោទន្តេ ទារកេ ទិស្វា | ឧព្វិគ្គា វិបុលា ទុមា |
| សយមេវោនមិត្វាន | ឧបគច្ឆន្តិ ទារកេ ។ |
| ឥទំ អច្ឆេរកំ ទិស្វា | អព្ភុតំ លោមហំសនំ |
| សាធុការំ បវត្តេសិ | មទ្ទី សព្វង្គសោភនា ។ |

Websites: WatKhemaraRatanaram.org or WatKhmers.org

អច្ឆេរំ វត លោកស្មឹ    អព្ភូតំ លោមហំសនំ
វេស្សន្តរស្ស តេជេន    សយមេវោនតា ទុមាតិ ។

ភោ សារីបុត្ត ហៃសារីបុត្តអើយ ឮដ៏កាលនោះ ព្រះរាជកុមារទាំងពីរទ្រង់ទតឃើញព្រៃព្រឹក្សា មានផ្លែត្រកាលក្នុងព្រៃធំ ក៏ទ្រង់ព្រះកន្សែងយំទារចង់បានផ្លែឈើទាំងនោះ ឯព្រៃព្រឹក្សាធំខ្ពស់ ហាក់ដូចបានឃើញព្រះរាជកុមារ ទ្រង់ព្រះកន្សែងសោយសោក ហាក់មានចិត្តអាសូរករុណា ក៏បង្អោនមែកចុះមករក ព្រះរាជកុមារទាំងពីរព្រះអង្គ ។ រីឯសម្ដេចព្រះរាជមទ្រី ដ៏ទ្រង់នូវលក្ខណាល្អព្រម ទ្រង់ទតយល់ហេតុអស្ចារ្យដូច្នោះហើយ ក៏កើតព្រឺព្រួចព្រះលោមា ទើបថ្វាយព្រះពរសព្វសាធុការថា អស្ចារ្យអ្វីមាល្បាយ មិនដែលមានក្នុងលោកនេះឡើយ ហេតុតែតេជះបុណ្យបារមីនៃព្រះវេស្សន្តរមហាសត្វ រីឈើឯណាខ្ពស់មិញ ក៏បង្អោនមែកចុះមកឯង ។

ឥតិ ជេតុត្តរនគរតោ សុវណ្ណគិរិតាលោ នាម បព្វតោ បញ្ច យោជនានិ ។ បពិត្រអើយ រីនឹងស្រដីគណនាឯចម្ងាយផ្លូវចេញទៅពីជេតុត្តរនគរនោះ ទៅដល់ភ្នំមួយឈ្មោះ សុវណ្ណគិរីតាល-

Websites: WatKhemaraRatanaram.org or WatKhmers.org

បពិតនោះចម្ងាយ ៥ យោជន៍, ពីនោះទៅដល់កោន្តិមារានទីចម្ងាយ ៥ យោជន៍, ពីកោន្តិមារានទីដល់ភ្នំមួយឈ្មោះអញ្ជនគិរីបពិតនោះចម្ងាយ ៥ យោជន៍, ពីនោះទៅដល់ស្រុកព្រាហ្មមួយឈ្មោះទុន្នវិដ្ឋនាលិទណ្ឌគ្រាមចម្ងាយ ៥ យោជន៍, តពីនោះទៅដល់មាតុលនគរចម្ងាយ ១០ យោជន៍ហោង ។

ឥតិ តំ វដ្ដំ ជេតុត្តរនគរតោ តឹសយោជនំ ហោតិ ។ ថាបើនឹងគណនាចម្ងាយផ្លូវពីជេតុត្តរនគរនោះ ៣០ យោជន៍ ហេតុទេវតាអាស្វរករុណាព្រះរាជបុត្រពុំងានោះមិញ ក៏បង្ហាញផ្លូវឲ្យទៀបជិត ស្ដេចដើរអំពីព្រឹកព្រហាមលុះដល់រសៀលបន្តិច ស្ដេចដល់មាតុលនគរនោះ ។ តេន វុត្តំ ហេតុនោះហោង ព្រះអង្គមានព្រះបន្ទូលនឹងព្រះមហាសារីបុត្តត្ថេរ សូត្រជាបាទព្រះគាថា ដូច្នេះ ៖

សង្ខិបឹសុ បថំ យក្ខា អនុកម្បាយ ជាតកេ
និក្ខន្តទិវសេនេវ ចេតរដ្ឋមុបាគមុន្តិ ។

ហៃសារីបុត្តអើយ រីព្រះមហាក្សត្រទាំង ៤ ព្រះអង្គ ស្ដេចចេញពីជេតុត្តរនគរនោះ ដោយនូវផ្លូវឆ្ងាយអម្បាលណោះក្ដី ហេតុតែ

ទេវតាអាសូរករុណាព្រះរាជបុត្រពុំងានោះមិញ ក៏បង្ហាញផ្លូវឲ្យទៀបជិត ថ្វាយព្រះមហាក្សត្រស្តេចលីលាចេញពីព្រឹក លុះដល់ថ្ងៃរសៀលបន្តិច ស្តេចដល់នគរចេតរាស្ត្រនោះហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ ។ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះអង្គបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលនឹងភិក្ខុផងទាំងឡាយ សូត្រសាជាអាថ៌បាទព្រះគាថាដូច្នេះ ៖

តេ គន្ត្វា ឱយមន្ទានំ ចេតរដ្ឋមុចាគមុំ
ឥទ្ធំ ផីតំ ជនបទំ ពហុមំសសុរោទកាន្តិ ។

ភិក្ខុអើយកាលក្សត្រទាំង ៤ អង្គ ស្តេចដើរដោយនូវផ្លូវឆ្ងាយ ដរាបទៅដល់ចេតរាស្ត្រនោះ ។ រីក្នុងស្រុកនោះសោត សឹងដ៏សំរិទ្ធិបរិបូណ៌ នូវអស់រាស្ត្រប្រជាជនផងទាំងឡាយ ដ៏ក្សេមក្សាន្តស្រណុក ប្រកបនូវបាយទឹកមាសប្រាក់រតនាករផងដ៏ច្រើន ។

តជា មតុលនគរេ សដ្ឋី ខត្តិយសហស្សានិ វសន្តិ ។ ឮដ៏កាលនោះ រីក្នុងមាតុលនគរនោះឯង មានមហាក្សត្រទាំង ៦ ម៉ឺន

Websites: WatKhemaraRatanaram.org or WatKhmers.org

សោយរាជ្យសម្បត្តិឋិតនៅនានគរនោះឯង នាកាលព្រះមហាក្សត្រទាំង ៤ ព្រះអង្គទៅដល់ហើយ ស្ដេចពុំចូលទៅក្នុងនគរនោះ ព្រះអង្គឡើងទៅគង់លើសាលាមួយ នៅឰដ៏ទ្វារនគរនោះហោង ។ កាលនោះសម្ដេចព្រះរាជមទ្រី ដ៏ជាអគ្គមហេសីស្រីវ័ត្ថប្រសើរ នាងចូលទៅបោសផង់ធូលី ដីខ្សាច់ ច្រចាច់គក់ព្រះបាទព្រះពោធិសត្វ ហើយនាងថ្វាយបង្គំ មកឋិតនៅខាងទ្វារសាលានោះ ឆ្ពោះត្រង់ព្រះភក្ត្រនៃព្រះមហាក្សត្រនោះឯង ។ រីអស់មហាជនផងទាំងឡាយ ទោះប្រុសក្ដីស្រីក្ដី ដើរចូលទៅក្នុងព្រះនគរនោះហើយ តែងរមិលមើលមកព្រះនាងមទ្រី ហើយស្គាល់ជាក្សត្រិយ៍ប្រកបនូវលក្ខណាដ៏ប្រសើរហើយ ស្រីទាំងនោះក៏ចូលទៅថ្វាយបង្គំនៅជាបរិវារបម្រើព្រះនាងហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ ។ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គសូត្រជាបាទគាថានឹងភិក្ខុផងទាំងឡាយថាដូច្នេះ ៖

ចេតិយោ បរិការិំសុ ទិស្វា លក្ខណាមាគតំ

Websites: WatKhemaraRatanaram.org or WatKhmers.org

សុខុមាលី វតាយយ្យា    បត្តិកា  បរិជារេតិ ។
វយ្ហាហិ បរិយាយិត្វា    សិវិកាយ រថេន ច
សាធុ មទ្ទី អរញ្ញស្មឹ    បត្តិកា  បរិជារេតីតិ ។

ហៃអស់ភិក្ខុផងទាំងឡាយអើយ  រីអស់ស្រីផងទាំងឡាយមកបម្រើជាបរិវារ ហើយទូលថា បពិត្រអ្នកនាងដ៏មានបុណ្យប្រសើរអើយ ព្រះនាងធ្លាប់គង់នៅស្រណុកសុខសប្បាយ ឥឡូវនេះអម្ចាស់មានទុក្ខអ្វីមកបៀតបៀនអម្ចាស់ ក៏អម្ចាស់មកតែព្រះបាទទទេ ឥតសុពណ៌បាទុកនឹងពាក់ឮដ៏ព្រះបាទ ។ បពិត្រក្សត្រិយ៍មានលក្ខណាប្រសើរអើយ រីគ្រែសុពណ៌សិវិកាក្តី រាជរថក្តី ដំរី ពាជី ពលថ្មើរជើងក្តីអម្ចាស់ទុកនៅឋានឯណា ក៏អម្ចាស់ស្តេចមកតែព្រះអង្គឯង ដោយនូវផ្លូវព្រៃធំនេះអម្ចាស់ ។ បពិត្រអើយ រីអស់អ្នកនគរផងទាំងឡាយនោះយល់ព្រះមហាក្សត្រទាំង ៤ ព្រះអង្គ លំបាកត្រមោចត្រមង់ឥតពំនាក់ដូច្នោះហើយ ក៏នាំគ្នាទួញយំរត់ចូលទៅទូលព្រះមហាក្សត្រទាំង ៦ ម៉ឺននោះ ។ រីអស់មហាក្សត្រទាំង ៦ ម៉ឺននោះសោត ទ្រង់ស្តាប់អស់ពាក្យមហាជនផងទូលដូច្នោះហើយ សឹងដ៏លើកព្រះហស្តដាក់លើត្បូង គក់

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះឱរាទ្រង់ព្រះកន្សែង ។ ស្តេចរត់ទៅកាន់សំណាក់ ព្រះពោធិសត្វមហាបុរសរ័ត្ន ឰដ៏កាលនោះហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ ។ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថៃងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គបន្ទូលនឹងអស់ភិក្ខុផងទាំងឡាយថាដូច្នេះ ៖

តំ ជិស្វា ចេតចាមោក្ខា  រោទមានា ឧចាគមុំ
កច្ចិ នុ ទេវ កុសលំ  កច្ចិ ទេវ អនាមយំ ។
កច្ចិ បិតា អរោគោ តេ  សិវីនញ្ច អនាមយំ
កោ តេ ពលំ មហារាជ  កោ នុ តេ រថមណ្ឌលំ ។
អនស្សកោ អរថកោ  ទីឃមទ្ធានមាគតោ
កច្ចាមិត្តេហិ បកតោ  អនុប្បត្តោសិមំ ទិសន្តិ ។

ភិក្ខុអើយ ឰដ៏កាលនោះ រីអស់មហាជនផង និងស្តេចចេតរាស្ត្រទាំង ៦ ម៉ឺន លុះឮពត៌មានអំពីព្រះពោធិសត្វហើយ ក៏ម្ទីម្ទាយកសំពត់អាវរតនាករ មកថ្វាយព្រះពោធិសត្វមួយរំពេច ហើយសឹងទ្រង់ព្រះកន្សែងជំឱរាអាសូរករុណា ព្រះមហាក្សត្របុរសរ័ត្ន និងព្រះនាង

Websites: WatKhemaraRatanaram.org or WatKhmers.org

មទ្រី ស្តេចលីលាមកដោយនូវព្រួយលំបាកពេកក្តាត់។ អស់ស្តេចចេតរាស្ត្រផងទាំងឡាយ ថ្វាយបង្គំព្រះពោធិសត្វបុរសរ័ត្ន ហើយសំណេះសំណាលក្រាបទូលសាកសួរថា «បពិត្រក្សត្រថ្លៃប្រសើរអើយ ព្រះអង្គនៅសព្វថ្ងៃនេះ សភាពឥតជម្ងឺតម្កាត់ ឬជាទុក្ខអផ្សុកក្នុងព្រះទ័យនៃមហារាជញ៉ាំងមាន ឬមួយព្រះអង្គនៅជាសុខសប្បាយពណ្ណរាយជាទេវីស្រីសួស្តី តើញ៉ាំងមានឬទេ រីសម្តេចព្រះវររាជមាតាបិតាព្រះអង្គឯនាយ តើញ៉ាំងមានព្យាធិរោគាជរាពាធជម្ងឺមកបៀតបៀនឬទេ រីអស់អ្នកស្រីពិរាស្ត្រ នូវពលសកលយោធា សេនាមាត្យទាំងឡាយនោះ តើញ៉ាំងជាសុខសប្បាយឬទេ រីសេនាដំរី សេនាសេះ សេនារទេះ សេនាពលថ្មើរជើង គ្រែសុពណ៌សិវិកា តើព្រះអង្គទុកនៅឋានឯណាក៏ព្រះអង្គស្តេចលីលាយាត្រាមកតែព្រះអង្គឯង ដោយនូវផ្លូវឆ្ងាយដូច្នេះ ក្រែងសត្រូវអ្វីមួយវាមកបៀតបៀនព្រះអង្គ ឬមួយគង់នៅសុខសប្បាយជាទេ ។

អថ ជេសំ សច្ចីសហស្សានំ រាជូនំ មហាសត្តោ អត្តនោ អាគតការណំ កថេន្តោ អាហ ។ ឮដំកាលនោះ ព្រះពោធិសត្វ

Websites: WatKhemaraRatanaram.org or WatKhmers.org

ស្តាប់ពាក្យអស់ស្តេចចេតរាស្ត្រទាំង ៦ ម៉ឺននោះហើយ ព្រះអង្គសម្តែងថ្លែងនូវសភាពអាការព្រះអង្គលីលាមកនោះ ទ្រង់មានព្រះបន្ទូលសូត្រនូវបាទព្រះគាថាដូច្នេះ

កុសលញ្ចេវ មេ សម្មា　　អថោ សម្មា អនាមយំ
អថោ បិតា អរោគោ មេ　　សិវីនញ្ច អនាមយំ ។
អហំ ហិ កុញ្ជរំ ទជ្ជំ　　ឦសាទន្តំ ឧរុឡ្ហវំ
ខេត្តញ្ញុំ សព្វយុទ្ធានំ　　សព្វសេតំ គជុត្តមំ ។
បណ្ឌុកម្ពលសញ្ឆន្នំ　　បភិន្នំ សត្តុមទ្ទនំ
ទន្តឹ សវាលវីជនឹ　　សេតំ កេលាសសាទិសំ
សសេតច្ឆត្តំ សុបត្ថេយ្យំ　　សាថព្វនំ សហត្ថិបំ
អគ្គយានំ រាជវាហឹ　　ព្រាហ្មណានំ អទា សហំ
តស្មឹ មេ សិវិយោ កុទ្ធា　　បិតា ចុបហតោ មនោ
អវរុទ្ធសិ មំ រាជា　　វង្កំ គច្ឆាមិ បព្វតំ
ឱកាសំ សម្មា ជានាថ　　វនេ យត្ថ វសេម្ហសេតិ ។

ហៃមហារាជអើយ រីសភាពជាទុក្ខអផ្សុកនោះ ឥតអង្គឹមាន ឡើយ មហាមិត្រអើយ រីស្រីសួស្តីសឹងមានដល់អញ ។ មហាមិត្រអើយ ប្រការមួយសោត សម្តេចព្រះវររាជមាតាបិតានៃយើង ឥតព្យាធិរោគាជរាមកបៀតបៀនព្រះអង្គឡើយ ។ រីអ្នកស្រីពិរាស្រ្តសោត សឹងឥតជម្ងឺតម្កាត់ទេសម្លាញ់អើយ រីដំណើរអញមកនេះ ត្បិតតែអញឲ្យទានដំរីបច្ច័យនាគេន្ទ្រនោះ ទៅព្រាហ្មណ៍ទាំង ៨ នាក់ រីដំរីនោះសោត សមធំចំរើនឡើងពេញកម្លាំង ដ៏មានភ្លុកងទន្ទាំហើយឈ្លាសដឹងសារពើចម្បាំងទាំងពួង ដ៏ជាបាដំរីធំប្រសើរក្រៃ អាចបុកបែនកិនញាំញីនូវសឹកសត្រូវផង ដ៏មានខ្លួននោះល្អសដូចភ្នំកៃលាសបពិត មានកន្ទុយល្គាយល្គងរាំងគន្លងបោសព្រះធរណី ដ៏ជាបាដំរីប្រសើរសមនឹងស្វេតច្ឆ័ត្ររាជសម្បត្តិ គួរជាជំនិះជំនាន់នៃមហាក្សត្រាធិរាជ ។ ហៃមហាមិត្រអើយ ត្បិតតែអញឲ្យដំរីបច្ច័យនាគេន្ទ្រនោះ ទៅជាទានព្រាហ្មណ៍ បានជាពួកអ្នកស្រីពិរាស្រ្តផងទាំងឡាយ នាំគ្នាខេខឹង ទាំងសម្តេចព្រះវររាជបិតា ក៏ទ្រង់ព្រះពិរោធនឹងអញ ហើយបំបរបង់អញពីស្រុក ឲ្យទៅនៅនាភ្នំគិរីវង្កតបពិតនោះហោង ។

Websites: WatKhemaraRatanaram.org or WatKhmers.org

តតោ រាជានោ អាហំសុ ។ ឮដំកាលនោះ រីអស់ស្តេចចេតរាស្ត្រទាំង ៦ ម៉ឺន ស្តាប់ព្រះបន្ទូលព្រះពោធិសត្វហើយក្រាបទូលថាដូច្នេះ ៖

ស្វាគតន្តេ មហារាជ អថោ តេ អទុរាគតំ
ឥស្សរោសិ អនុប្បត្តោ យំ ឥធត្ថិ បវេទយ ។
សាកំ ភឹសំ មធុំ មំសំ សុទ្ធំ សាលិនមោទនំ
បរិភុញ្ជ មហារាជ ចាហុនោ នោសិ អាគតោតិ ។

បពិត្រក្សត្រថ្លៃប្រសើរអើយ នាដំណើរព្រះអង្គលីលាមកនេះ ក៏យល់ប្រសើរក្រៃពេកណាស់ មិនហាក់ជាព្រះអង្គលីលាមកពីចម្ងាយនោះឡើយ ហាក់ដូចព្រះអង្គនៅអាយមួយអន្លើ នូវអស់យើងខ្ញុំ ។ បពិត្រមហារាជអើយ ទោះក្រឪឈូកក្តី ព្រលិតលំចង់ក្រចាប់ក្តី យកមកប្រទ្បុំនីទៅនូវទឹកឃ្មុំ ដ៏ប្រកបនូវបាយទឹក ភោជ្ជសាលីបរិសុទ្ធសឹងសល្អប្រពៃ ដ៏ប្រកបនីទៅនូវត្រីសាច់ញាំភ្លាផងទាំងឡាយច្រើន សូមអញ្ជើញព្រះអង្គសោយរាជសម្បត្តិ ឋិតនៅជាឥស្សរកំពូលនៃយើងខ្ញុំ នៅនានគរនេះហោង ។ ព្រះបាទស្រីវេស្សន្តបវរពោធិសត្វ

Websites: WatKhemaraRatanaram.org or WatKhmers.org

ស្តាប់ពាក្យស្តេចចេតរាស្ត្រទាំង ៦ ម៉ឺននោះហើយ ព្រះអង្គមានព្រះបន្ទូលវិញជាបាទព្រះគាថាដូច្នេះ ៖

បដិក្ខហិតំ យំ ជិន្នំ　　សព្វស្ស អត្ថិយំ កតំ

អវរុទ្ធសិ មំ រាជា　　វង្កំ គច្ឆាមិ បព្វតំ

ឱកាសំ សម្មា ជានាថ　　វនេ យត្ថ វសេម្ហសេតិ ។

សម្មា ហែសម្លាញ់ទាំងឡាយអើយ វិទ្រព្យឯណាមិញជាទ្រព្យទទួលភ្ញៀវ ក៏មហាមិត្រយកមកឲ្យយើង, យើងនឹងទទួលយកដែរ ប៉ុន្តែសម្តេចព្រះមហាក្សត្រ ទ្រង់ព្រះពិរោធនឹងយើង, យើងត្រូវទៅកាន់ភ្នំគិរីវង្កត សុំឲ្យមហាមិត្រណែផ្លូវយើង, យើងទៅនៅភ្នំគិរីវង្កតបពិតនោះហោង ។

តេ រាជានោ អាហំសុ ។ អស់ស្តេចចេតរាស្ត្រផងទាំងឡាយស្តាប់ព្រះបន្ទូលព្រះបរមពោធិសត្វ ហើយក្រាបបង្គំទូលវិញ សូត្រជាបាទព្រះគាថាដូច្នេះ ៖

តថេវ តាវ អច្ឆស្សុ　　ចេតរដ្ឋេ រថេសភ

យាវ ចេតា គមិស្សន្តិ　　រញ្ញោ សន្តិក យាចិតុំ

Websites: WatKhemaraRatanaram.org or WatKhmers.org

និជ្ឈាបេតុំ មហាភជំ    សិរីនំ វេជ្ជវេឡ្ងនំ
តំ តំ ចេតា ឬរក្ខិត្វា    បតីតា លទ្ធបច្ចយា
បរិវារេត្វាន គច្ឆន្តិ    ឯវំ ជាណាហិ ខត្តិយាតិ ។

បពិត្រព្រះសម្មតិទេព មហាក្សត្រថ្លៃប្រសើរអើយ សូមទានអម្ចាស់សោយរាជ្យនៅនានគរយើងខ្ញុំនេះ ក៏យើងខ្ញុំទាំង ៦ ម៉ឺននេះនឹងទៅទូល ព្រះបាទស្រីសញ្ជ័យ ប្រាប់អស់អ្នកស្រីពិរាស្រ្តផងទាំងឡាយ ឲ្យគេអត់ទោសព្រះអង្គ ។ បពិត្រមហារាជអើយ រីអស់អ្នកស្រីពិរាស្រ្តនោះ កាលបើគេដឹងថាព្រះបាទសញ្ជ័យ អត់ទោសព្រះអង្គហើយ ក៏អ្នកស្រីពិរាស្រ្ត គេនឹងមកចោមរោមបម្រើជាបរិវារព្រះអង្គនោះច្រើនក្តាត់ហោង ។

មហា សត្តោ អាហ ។ ព្រះមហាសត្វស្តាប់ពាក្យស្តេចចេតរាស្រ្តនោះហើយ ព្រះអង្គមានព្រះបន្ទូលនូវអាថ៌បាទព្រះគាថាដូច្នេះ

មា វោ រុចិត្ថ គមនំ    រញ្ញោ សន្តិកា យាចិតុំ
និជ្ឈាបេតុំ មហារាជំ    រាជាបិ តត្ថ និស្សរោ ។
អច្ចុគ្គតា ហិ សិវិយោ    ពលគ្គា នេគមា ច យេ

Websites: WatKhemaraRatanaram.org or WatKhmers.org

តេ បជំសេតុមិច្ឆន្តិ រាជានំ មម ការណាតិ ។

ហៃមហាមិត្រអើយ ចូរអ្នកទាំងឡាយ ស្តាប់ពាក្យយើង, យើងនឹងសម្តែងថ្លែងប្រាប់ថា បើយើងបានទទួលសោយរាជសម្បត្តិនៅនានគរនោះហើយ រីជំណៀលពីរប្រការនឹងកើតមានប្រាកដ គឺអ្នកស្រីពិរាស្ត្រគេនឹងត្មះតិះដៀលយើងថា «ឱព្រះវេស្សន្តរអើយ សោយរាជសម្បត្តិមិនឋិតនៅដោយគន្លងធម៌» គេយល់ដូច្នោះហើយ បានជាគេបំបរបង់ចេញពីស្រុក ឲ្យទៅនៅភ្នំគិរីវង្កតបពិត ឆ្ងាយប្រការមួយហើយប្រការមួយទៀត ឥឡូវនេះមកយល់តែគេឃាត់ឲ្យសោយរាជ្យដូច្នោះកូវ ក៏សោយរាជ្យព្រងើយ ។ ហៃមហាមិត្រអើយ រីអស់អ្នកថានឹងទៅទូលព្រះបាទស្រីសញ្ជ័យ ឲ្យអ្នកអត់ទោសយើងនោះ ពុំគួរដល់អ្នកទាំងឡាយឡើយ រីព្រះបាទស្រីសញ្ជ័យ ព្រះអង្គជាស្តេចធំ ឧត្តមប្រសើរកន្លង រំលងអស់រាស្ត្រប្រជាជនទាំងឡាយមែនពិត គឺមោះអស់អ្នកស្រីពិរាស្ត្រផងទាំងឡាយគេខឹង ហើយគេជំនុំគ្នានូវអស់នាយដំរី នាយសេះ នាយរទេះ នាយពល ក្រៅលំនៅជនបទផងទាំងឡាយគេនឹងសម្លាប់ព្រះអង្គ ត្បិតតែយើងនេះឯង ទើបយើងរត់មកឥឡូវនេះ។

ហែមហាមិត្រអើយ ថាបើដឹងព្រៃឯណាស្រណុកសុខសប្បាយ ចូរអ្នកទាំងឡាយប្រាប់យើង, យើងនឹងទៅនៅនាព្រៃនោះហោង ។

តតោ រាជានោ អាហំសុ ។ អណ្តាប់នោះ អស់ស្តេចចេតរាស្ត្រផងទាំងឡាយ ស្តាប់ព្រះបន្ទូលព្រះបរមពោធិសត្វហើយ ទូលជាបាទព្រះគាថាថា ៖

សចេ ឯសា បវត្តេត្ថ　　　រដ្ឋស្មឹ រដ្ឋវឌ្ឍន

ឥតេវ រជ្ជំ ការេហិ　　　ចេតេហិ បរិវារិតោ

ឥទ្ធំ ផីតញ្ចិទំ រដ្ឋំ　　　ឥន្ទោ ជនបទោ មហា

មតឹ ករោហិ ត្វំ ទេវ　　　រដ្ឋស្សមនុសាសិតុន្តិ ។

បពិត្រព្រះអង្គ តែងទ្រង់ធ្វើសេចក្តីចំរើន ដល់អ្នកស្រីពិរាស្ត្រអើយ បើមានហេតុកើតឡើងក្នុងដែននោះក្ងរ សូមព្រះអង្គគ្រងរាជសម្បត្តិក្នុងនគរយើងខ្ញុំនេះ សឹងមានស្តេចចេតរាស្ត្រទាំងឡាយ ចោមរោមជារាជបរិវារ ។ មួយសោត ដែនចេតរាស្ត្រនេះ ក៏ធំទូលាយស្តុកស្តម្ភសម្បូណ៌ បពិត្រក្សត្រថ្លៃប្រសើរអើយ សូមព្រះអង្គព្រមទទួលដើម្បីគ្រប់គ្រងរាជ្យសម្បត្តិជាឥស្សរនៃយើងខ្ញុំហោង ។

Websites: WatKhemaraRatanaram.org or WatKhmers.org

តតោ វេស្សន្តរោ អាហ។ បពិត្រអើយ រីព្រះបាទស្រីវេស្សន្តរ បរមពោធិសត្វ ស្តេចស្តាប់អស់ពាក្យស្តេចចេតរាស្ត្រទាំង ៦ ម៉ឺន ទូលអង្វរអញ្ជើញព្រះអង្គ ឲ្យសោយរាជ្យសម្បត្តិស្វេតច្ឆ័ត្រ គ្រងព្រះនគរដូច្នោះក្ដី ព្រះអង្គមានព្រះបន្ទូលដោះសា នឹងអស់ស្តេចចេតរាស្ត្រផងទាំងឡាយថា ៖

ន មេ ឆន្ទោ មតិ អត្ថិ  រជ្ជស្សមនុសាសិតុំ
បព្វាជិតស្ស រដ្ឋស្មា  ចេតបុត្តា សុណាថ មេ ។
អតុដ្ឋា សិវិយោ អស្សុ  ពលត្ថា នេគមា ច យេ
បព្វាជិតស្ស រដ្ឋស្មា  ចេតា រជ្ជេភិសេចយុំ ។
អសម្មោទិយំបិ វោ អស្ស  អច្ចន្តំ មម ការណា
សិវីហិ ភណ្ឌនញ្ចាបិ  វិគ្គហោ មេ ន រុច្ចតិ ។
អថស្ស ភណ្ឌនំ ឃោរំ  សម្បហារោ អនប្បកោ
ឯកស្ស ការណា មយ្ហំ  ហឹសេយ្យ ពហុកោ ជនោ ។
បដិគ្គហិតំ យំ ទិន្នំ  សព្វស្ស អគ្ឃិយំ កតំ

Websites: WatKhemaraRatanaram.org or WatKhmers.org

អវរុទ្ធសិ មំ រាជា វដ្ឋំ កច្ឆាមិ បព្វតំ
ឱកាសំ សម្មា ជាជាថ វេដ យត្ថ វសេម្ហសេតិ ។

ហែមហាមិត្រអើយ បើយើងសោយរាជ្យសម្បត្តិ នៅនគរនេះហើយ សមអ្នកស្រីពិរាស្រ្តផងទាំងឡាយ គេនឹងបរពលសកលយោធាសេនាមាត្យ លើកទ័ពមីរដេរដាស ដោយពាសពេញទាំងក្រឡាមហាប្រឹថពី ខ្មីឃ្មាតសង្ឃាតមកចោមរោមមាតុលនគរនេះ ប្រាកដមិនទេឡើយ ។ ហែសម្លាញ់អើយ ម្ល៉ោះហើយក៏វានឹងកើតជាកោលាហលអំពល់នូវចម្បាំងរាំងជល់ប្រកាប់ប្រចាក់គ្នា រីអស់មនុស្សម្នាមហាជនផងទាំងឡាយនោះ សឹងស្លាប់ច្រើនពុំខានឡើយ ។ ហេតុនេះហោង វាមិនកើតមកអំពីអ្នកណាឡើយ វាកើតត្បិតយើងមកសោយរាជ្យសម្បត្តិនេះឯង ។ ហេតុនេះហើយ យើងមិនទើងនៅសោយរាជសម្បត្តិឡើយសម្លាញ់អើយ ។ ថាបើសម្លាញ់អាសូរយើងហើយ ក៏យើងសូមតែស្បៀងឆីរៀង ៗ ទៅដោយផ្លូវ ។ ត្បិតអ្នកស្រីពិរាស្រ្តគេបំបរបង់យើងចេញ ក៏យើងនឹងទៅនាភ្នំគិរីវង្កតបពិតនាយហោង ។

ឯវញ្ច បន វត្វា មហាសត្តោ អនេកាបរិយាយេន

Websites: WatKhemaraRatanaram.org or WatKhmers.org

យាចិតោបិ វឌ្ឍំ ឧ ឥច្ឆិ ។ រីព្រះមហាសត្វ ព្រះអង្គនាំបរិយាយ និយាយមកជាសណ្តាប់ ប្រាប់ស្តេចចេតរាស្ត្រផងទាំងឡាយនោះច្រើន ហេតុតែព្រះអង្គមិនចង់សោយរាជ្យសម្បត្តិឡើយ ហើយអស់ស្តេចចេតរាស្ត្រផងទាំឡាយ សឹងបូជាឲ្យសព្ទសាធុការ ដល់មហាបុរសរ័ត្ននោះច្រើន ហើយក្រាលនីទៅនូវកម្រាលចៀមចំព្រៃព្រំ បាំងនូវនាំងវាំងនន ការពារពិភ័ក្តិរក្សាព្រះបរមពោធិសត្វ នៅនាសាលានោះហោង ។

បពិត្រអើយ លុះព្រឹកព្រហាមឡើងវិញ ព្រះអង្គស្តេចលីលាទៅកក់ស្រង់ជម្រះ នូវព្រះកេសាប្រដាប់អាត្មា ពីព្រហាមស្រេច ស្តេចសោយនូវភោជនាហារ ដ៏មានរសពិសាស្រេចហើយ ស្តេចលីលាចេញទៅអំពីសាលាមួយអន្លើ នឹងអស់ស្តេចចេតរាស្ត្រផងទាំងឡាយសឹងមកចោមរោមជារាជបរិវារហោង ។ ព្រះបរមពោធិសត្វនិងអស់ស្តេចចេតរាស្ត្រទាំង ៦ ម៉ឺន ស្តេចលីលាទៅដល់ទ្វារព្រៃភ្នំគិរីវង្កតបពិតដ៏មានចម្ងាយផ្លូវនោះ ១៥ យោជន៍ កាលអស់ស្តេចចេតរាស្ត្រ ក្រាបទូលណែនាំផ្លូវព្រះពោធិសត្វទៅខាងមុខ សឹងដ៏មានចម្ងាយ ១៥

Websites: WatKhemaraRatanaram.org or WatKhmers.org

យោជន៍ ទើបសូត្រជាបាទព្រះគាថាដូច្នេះ ៖

តស្ស តេ មយមក្ខាម    យថាបិ កុសលា តថា
រាជិសី យត្ថ សម្មន្តិ    អាហុតគ្គី សមាហិតា ។
ឯស សេលោ មហារាជ    បព្វតោ គន្ធមាទនោ
យត្ថ ត្វំ សហ បុត្តេហិ    សហ ភរិយាយ ចច្ឆសិ ។
តំ ចេតា អនុសាសឹសុ    អស្សុនេត្តា រុទម្មុខា
ឥតោ គច្ឆ មហារាជ    ឧជុំ យេនុត្តរាមុខោ ។
អថ ទក្ខសិ ភទ្ទន្តេ    វេបុល្លំ នាម បព្វតំ
នានាទុមគណាកិណ្ណំ    សីតច្ឆាយំ មនោរមំ ។
តមតិក្កម្ម ភទ្ទន្តេ    អថ ទក្ខសិ អាបគំ
នទឹ កេតុមតឹ នាម    គម្ភីរំ គិរិគព្ភរំ ។
បុថុលោមមច្ឆាកិណ្ណំ    សុបតិត្ថំ មហោទកំ
តត្ថ ន្ហាត្វា បិវិត្វា ច    អស្សាសេត្វា សបុត្តកេ ។
អថ ទក្ខសិ ភទ្ទន្តេ    និគ្រោធំ មធុបិប្ផលំ ។

រម្មកោ សិខរេ ជាតំ សីតច្ឆាយំ មនោរមំ ។
អថ ទក្ខសិ ភទ្ទន្តេ នាលិកំ នាម បព្វតំ
នានាទិជគណាកិណ្ណំ សេលំ កឹបុរិសាយុតំ
តស្ស ឧត្តរបុព្វេន មុចលិន្ទោ នាម សោ សរោ ។
បុណ្ឌរីកេហិ សញ្ឆន្នោ សេតសោគន្ធិយេហិ ច
សោ វនំ មេឃសង្កាសំ ធុវំ ហរិតសទ្ទលំ ។
សីហោវាមិសបេក្ខីវ វនសណ្ឌំ វិគាហិយ
បុប្ផរុក្ខេហិ សញ្ឆន្នំ ផលរុក្ខេហិ ចូភយំ ។
តត្ថ ពិន្ទុស្សរា វគ្គូ នានាវណ្ណា ពហូ ទិជា
កូជន្តមុបកូជន្តិ ឧតុសម្បុប្ផិតេ ទុមេ ។
គន្ត្វា គិរិវិទុគ្គានិ នទីនំ បភវានិ ច
សោ អទ្ទស បោក្ខរណឹ ករញ្ជកកុធាយុតំ ។
បុថុលោមមច្ឆាកិណ្ណំ សុបតិត្ថំ មហោទកំ
សមញ្ច ចតុរស្សញ្ច សាទុំ អប្បដិគន្ធិយំ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

តស្សា ឧត្តរបុព្វេន បណ្ណសាលំ អមាបយ
បណ្ណសាលំ អមាបេត្វា ឧញ្ឆាចរិយាយ ឡៀហជាតិ ។

បពិត្រ ព្រះសម្មតិទេពក្សត្រថ្លៃប្រសើរអើយ ព្រះអង្គរមិលមើលទៅភ្នំនោះ យល់ប្រាកដលោកសន្មត ហៅភ្នំគន្ធមាទន៍បពិត ព្រះអង្គស្តេចចេញពីនោះទៅបន្តិច នឹងដល់ភ្នំមួយឈ្មោះវិបុលបពិត ដ៏មីរដេរដាសនីទៅនូវដើមឈើតូចធំ ផងទាំងពួងនោះច្រើន ដ៏មានមែកនោះវែងលលាយត្រសាយសាខា បុប្ផាសន្លឹក ដ៏មានម្លប់នោះត្រជាក់ស្រណុកសុខសប្បាយ ។ មួយសោត រីជោតមាណពផងទាំងឡាយសឹងដ៏អាស្រ័យពំនាក់នៅនាឋាននោះហោង ហើយព្រះអង្គកន្លងរំលងពីនោះទៅទៀត ព្រះអង្គនឹងបានដល់យល់ស្ទឹងមួយឈ្មោះ កេតុមតីនទី ដ៏មានទឹកនោះជ្រៅថ្លាត្រជាក់ ស្រណុកសុខសប្បាយ ប្រាសចាកស្លែសារាយសំរាមព្រាំផងទាំងឡាយ ដ៏មីរដេរដាសពាសពេញនីទៅនូវត្រីផងទាំងឡាយសឹងដ៏ធំ ៗ ហើយមានច្រាំងនោះទាប មានកំពង់នោះរាបស្មើ ដ៏មានទឹកនោះច្រើន សូមព្រះអង្គស្រង់ជម្រះព្រះវរកាយលោមព្រះរាជបុត្រព្រះរាជទេពី រួចសឹមស្តេចលីលាចេញពីនោះទៅ

Websites: WatKhemaraRatanaram.org or WatKhmers.org

បន្តិច នឹងបានឃើញដើមជ្រៃ ១ ធំ ដ៏មានផ្លែនោះទុំក្រហមច្រាលរន្ទាល មានឱជារសផ្អែមបីដូចទឹកឃ្មុំ ដ៏មានមែកនោះត្រសាយសាខា មានម្លប់ត្រជាក់ស្រណុកសប្បាយ ហើយអម្ចាស់នឹងសោយផ្លែជ្រៃនោះមួយអន្លើ នឹងព្រះរាជបុត្រព្រះរាជទេពីនៅនាឋាននោះហោង ។ មួយសោត ព្រះអង្គស្តេចលីលាពីនោះទៅ នឹងបានឃើញភ្នំមួយឈ្មោះនាលិកបព៌ត ដ៏ដេរដាសសឹងដ៏ថ្មល្អប្រពៃ ពេញនីទៅនូវបក្សីផងទាំងឡាយគឺកិន្នរី កិន្នរា សឹងដ៏ច្រៀងរាំបីដូចភ្លេងល្បែងរបាំមាននៅនាសួគ៌ទេពលោកនាយហោង ។

បពិត្រអើយ បើស្តេចលីលាទៅ ដោយប្របជើងនាលិកបព៌ត ដោយនៅខាងទិសឧត្តរនោះ ស្តេចនឹងបានឃើញស្រះ ១ លោកហៅថាមុចលិន្ទស្រះ ដ៏ដាសពាសពេញនីទៅនូវឈូកស ឈូកច្រាល កុមុទ ឧត្បល លំចង់ ស្គន់ ស្បង្កជ ព្រលិត ត្រកួន កំពឹងពួយ ផងទាំងឡាយច្រើន ។ អម្ចាស់ចូលទៅក្នុងកំឡុងព្រៃនោះហើយ ក៏នឹងបានឃើញស្មៅជើងក្រាស់ សឹងដ៏ដុះដាសពេញ មានពណ៌ខ្មៅ ខៀវខ្ចីបីដូចផ្ទៃមហាមេឃ ។ រីស្មៅនោះសោត ក៏ដុះពាសពេញទាំងព្រៃនោះ

Websites: WatKhemaraRatanaram.org or WatKhmers.org

សឹងជាលំនៅនៃរាជសីហ៍ដំរីព្រៃផងទាំងឡាយនោះ ។ មួយសោត បពិត្រក្សត្រថ្លៃប្រសើរអើយ រីបក្សីផងទាំងឡាយនោះ សឹងមានកំណើតពីរដង គឺជាពងហើយញាស់ជាកូន នៅសងខាងដងព្រៃនោះ សឹងដ៏ស្រែកកញ្ជ្រៀវខ្ញៀវខ្ញារ ដ៏មានសម្លេងនោះពីរោះផ្សេងៗ ហើយយំទំលើឈើមានផ្លែផ្កា រីកស្គុះស្គាយដោយរដូវហោង ។ បពិត្រអម្ចាស់អើយ រីព្រៃនោះសោត ដ៏ប្រកបនីទៅនូវឈើផង មានពីរចំពូក មួយគឺឈើមានផ្លែ មួយគឺឈើមានផ្កា ។ ថាបើអ្នកឯណាមួយ បានទៅដល់យល់ឈើនោះហើយ សឹងដ៏មានចិត្តនោះ ស្រណុកសុខសប្បាយពណ្ណរាយក្រៃពេក សឹងដ៏មានក្លិននោះពិដោរក្រៃលែង នៃភ្ញីផ្កាផងទាំងឡាយហោង ។ បពិត្រអម្ចាស់អើយ ស្តេចនឹងបានយល់ស្ទឹងមួយ ដ៏មានទឹកនោះហូរចុះមកអំពីភ្នំវង្កតនោះឯង ។ អណ្តាប់នោះស្តេចនឹងបានយល់ស្រះបោក្ខរណី ដ៏មានទន្លា ស្នាយទឹកពេញនីទៅនូវត្រីផងទាំងឡាយសឹងដ៏ធំៗ ស្រះនោះសោតមានមុំ ៤ មានច្រាំងទាប មានកំពង់រាបស្រណុក មានទឹកនោះច្រើន ដ៏ប្រកបនីទៅនូវក្លិនភ្ញីផ្កាផងទាំងឡាយ ។ បពិត្រអម្ចាស់អើយ កាលបើអម្ចាស់ទៅដល់ឋាន

Websites: WatKhemaraRatanaram.org or WatKhmers.org

នោះហើយ ចូរអម្ចាស់សម្រាន្តនៅនាទិសឯជើង នៃស្រះបោក្ខរណី នោះ អម្ចាស់ស្វែងរកមើមឈើ ផ្លែឈើទាំងឡាយសោយចិញ្ចឹមជីវិត នៅនាឋាននោះឯង ស្រណុកសុខសប្បាយមហិមាក្រៃពេកហោង ។

ឯវំ ចេតរាជានោ តស្ស បណ្ណរសយោជនមគ្គំ អាចិក្ខិត្វា ។ បពិត្រអើយ រីអស់ស្តេចចេតរាស្រ្តផងទាំងឡាយ ទូលបង្ហាញផ្លូវ ១៥ យោជន៍ ប្រាប់ព្រះពោធិសត្វមហាបុរសវត្ថស្រេច ហើយ ក៏ជូនដំណើរព្រះពោធិសត្វទៅ ។ រីព្រះពោធិសត្វសោត ទ្រង់ស្តាប់ពាក្យស្តេចចេតរាស្រ្តហើយ ក៏ស្តេចមានព្រះបន្ទូលលាលីលាទៅហោង ។ ឲ្យដំកាលនោះ រីអស់ស្តេចចេតរាស្រ្តទាំង ៦ ម៉ឺន នោះមកពិចារណាថាដូច្នេះ ភោន្តោ រាជានោ ហៃអស់មហាក្សត្រផងទាំងឡាយ អើយ បើដោយយើងគិតនេះហើយ សមសត្រូវផងទាំងឡាយ ខ្លាចក្រែងវាតាមមកធ្វើទុក្ខធ្វើទោសព្រះអង្គ នៅនាកម្លុងព្រៃនោះហោង ។ មហាក្សត្រទាំង ៦ ម៉ឺននោះ គិតព្រមគ្នាដូច្នោះហើយ ស្តេចឲ្យជ្រើសរើសយកកូនអ្នកស្រុកចេតរាស្រ្តមួយនាក់ ឈ្មោះចេតបុត្ត ជាអ្នកឈ្លាសខាងសិល្ប៍ធ្នូមុតមែនក្វែនស្នាត់ ។ ស្តេចបន្ទូលផ្តាំថាដូច្នេះ ហៃ

បាចេតបុត្តអើយ បាឯងជាអ្នកឧស្សាហ៍ព្យាយាម ដើរត្រាច់រង្គាត់ច្រវាត់ទៅមក រកបរបាញ់ម្រឹគបក្សី ចូរបាយកអាសាយើង ទៅនៅនាទ្វារព្រៃនោះ ហើយបាពិចារណាឲ្យដឹងអស់សេចក្តី ទោះអ្នកឯណាមួយដើរចូលទៅក្តី ទោះបីអ្នកដំណើរថ្មើរព្រៃក្តី ក៏បាពិចារណាឲ្យជាក់ ខ្លាចវាទៅធ្វើទុក្ខធ្វើទោសព្រះបាទស្រីវេស្សន្តរនោះហោង ។ បពិត្រអើយ រីក្សត្រទាំង ៦ ម៉ឺននោះ គិតជំនុំព្រមគ្នាដូច្នោះហើយ ក៏ប្រើចៅចេតបុត្តឲ្យទៅនៅចាំរក្សាទ្វារព្រៃនោះហើយក្តី ក៏វិលក្រឡាប់ទៅកាន់ព្រះនគរអាត្មាវិញហោង ។

វេស្សន្តរោបិ សបុត្តទារោ គន្ធមាទនំ បត្វា ។ បពិត្រអើយ ឮដ៏កាលនោះ ព្រះបាទស្រីវេស្សន្តរ ស្តេចចេញទៅមួយអន្លើនឹងព្រះរាជបុត្រព្រះរាជទេពី ទៅឈប់សម្រាន្តឮដ៏ភ្នំគន្ធមាទន៍បព៌ត លុះព្រឹកព្រហាមឡើង ស្តេចលីលាឆ្ពោះទៅដោយទិសឧត្តរ ខាងឯជើងភ្នំវិបុលបព៌តនោះហោង ។ ស្តេចទៅគង់នាឆ្នេរស្ទឹងកេតុមតីនទី កាលនោះមានថ្មើរព្រៃ ១ មកថ្វាយសាច់ក្រៀម នឹងទឹកឃ្មុំផ្លិត ព្រះអង្គសោយលោមព្រះរាជបុត្រព្រះរាជទេពី ហើយព្រះអង្គស្វាបព្រះកេសា ប្រវា

Websites: WatKhemaraRatanaram.org or WatKhmers.org

យកឯស្មៀតសក់មាសមួយមក ព្រះរាជទានទៅថ្មើរព្រៃនោះ ហើយស្ដេចនាំព្រះរាជបុត្រព្រះរាជទេពី ចុះទៅស្រង់ទឹកបន្ទោបង់នូវញើសក្អែលស្រេចហើយ ស្ដេចឡើងមកគង់សម្រាន្តបន្តិច នាម្លប់ជ្រៃមានឰដ៏ខាងភ្នំនោះ ។ ស្ដេចឈោងបេះផ្លែឈើ មកសោយមួយអន្លើនឹងព្រះរាជបុត្រព្រះរាជទេពីស្រេចហើយ ស្ដេចទៅដល់ភ្នំនាលិកបពិត ស្ដេចដើរកន្លងពីនោះទៅដល់មុចលិន្ទស្រះស្រង់ត្រង់មុំឧត្តរ ស្ដេចដើរដោយព្រៃនោះទៅកូវ យល់ផ្លូវមួយចុះតែជើងអ្នកមួយដើរទៅបានហោង ។ ស្ដេចដើរកន្លងពីទីនោះទៅដល់ជ្រោះភ្នំមួយ ដ៏ជាកំណើតនៃស្ទឹងផងទាំងឡាយ ដ៏មានទឹកនោះហូរពុំដែលដាច់ឡើយ ។ ហើយព្រះអង្គដើរកន្លងរំលេងពីនោះទៅឯភ្នែក ដល់ឆ្នេរស្រះបោក្ខរណីនោះហោង ។

តស្មឹំ ខណេ សក្កភវនំ ឧណ្ហាការំ ទស្សេសិ ។

បពិត្រអើយ កាលណាបើព្រះពោធិសត្វ មហាបុរសវ័ត្នវិសេស ស្ដេចចូលទៅដល់ភ្នំវង្កតបពិតនោះហើយ រីបណ្ដូកម្ពលសិលាអាសន៍ ដ៏ជាអាសនៈនៃសម្ដេចអមរិន្ទ្រាធិរាជ ដ៏ជាក្រឡាគម្ដែងនៃព្រះនាងសុជាតា ក៏កើតជានិម្មិតក្ដៅក្រហាយ នឹងគង់នៅជាសុខសប្បាយ

ពុំបានឡើយ ។ ក្សិណនោះ ព្រះឥន្ទ្រាធិរាជ ដ៏ជាម្ចាស់នៃទេវតាផង ទាំងឡាយ ស្ដេចទ្រង់ព្រះចិន្ដាពិចារណាថា ឱ! នាកើតកោលាហល វល់អស្ចារ្យទាំងម៉្លេះ សមជាព្រះមហាក្សត្រ ស្ដេចចូលមកកាន់ព្រៃព្រះ ហេមពាន្ដនេះឯង ។ ឱ! ដូចអញគិតនេះហើយ វិឋាននេះក៏សមគួរនឹង ព្រះមហាក្សត្រ ព្រះអង្គគង់សាងព្រះផ្នួសហោង ។ កាលនោះសម្ដេច ព្រះឥន្ទ្រាធិរាជតែងនឹងទ្រង់បំពេញបារមី នៃព្រះពោធិសត្វរៀងមក ស្ដេចបន្ទូលហៅព្រះវិស្សកម្មទេវបុត្រថាដូច្នេះ ៖

គច្ឆ តាត ត្វំ វង្កតបព្វតកុច្ឆិម្ហិ រមណីយេ ឋានេ អស្សមបទំ មាបេត្វា ឯហីតិ វិស្សកម្មំ បេសេសិ ។ ថាម្នាល វិស្សកម្មទេវបុត្រអើយ ចូរអ្នកទៅកាន់ឋានមនុស្សលោក ហើយសាង អាស្រមបទនៅនាចង្កេះភ្នំគិរីវង្កត ឲ្យជាទីក្សេមសម្រាន្ដព្រះទ័យ នៃ ព្រះមហាសត្វហោង ។

សោ សាធូតិ សម្បដិច្ឆិត្វា ទេវលោកតោ ឱតរិត្វា ។ បពិត្រអើយ រីព្រះវិស្សកម្មទេវបុត្រទទួល នូវព្រះបន្ទូលសម្ដេចព្រះ ឥន្ទ្រាធិរាជហើយឆ្លើយថា «សាធុៗ គាប់ហោង» ។ ស្រេចហើយ ក៏

Websites: WatKhemaraRatanaram.org or WatKhmers.org

ហោះមកពីសួគ៌ទេពលោកនាយ ចូលទៅកាន់កម្លុងក្នុងព្រៃភ្នំវង្កតបពិត នោះហើយ និម្មិតបរមសាលានោះពីរ ឋានចង្រ្កមនោះពីរ គឺមួយជាលំនៅយប់ មួយជាឋានក្រសាលថ្ងៃ។ រីចុងចង្រ្កមណ៍សោត ដ៏ប្រដាប់នីទៅនូវឈើផងទាំងឡាយដ៏វិចិត្រ នូវផ្លែផ្កានោះផ្សេងៗ ដ៏ប្រកបនីទៅនូវចេកស្នែង ចេកដងខ្វែង ចេកកាប្អូរ ចេកឥតត្រយូង ចេកអំបូង ចេកស្នែងពពៃ ចេករាជសីហ៍ ចេកមហាថ្លៃ ចេកម្រាមដៃនាង ចេកផេះ ចេកនួន ចេកពងមាន់ ដ៏មាននូវអំពៅតំឡាន់ អំពៅក្តាម អំពៅត្រែង ដ៏ប្រកបនីទៅនូវដំឡូងទៀន ដំឡូងទឹក ដំឡូងពងលលក ដំឡូងពងប្រវឹក ដំឡូងបាស ដំឡូងក្រាមវិមាស ដំឡូងដៃខ្លា ដំឡូងខ្យា ដំឡូងស្រំផ្សំនូវដំឡូងស្រូវ ដំឡូងឈាមមាន់ រាជព័ន្ធនូវដំឡូងពស់ ដំឡូងផ្កា ។ ស្រេចសព្វគ្រប់ព្រមទាំងគ្រឿងបរិក្ខារអ្នកបួសនោះហោង ។ ស្រេចហើយក៏សរសេរត្រាត្រូចផ្តួចធ្វើជាអក្ខរា នៅនាខ្លោងទ្វារព្រះបរមសាលានោះថាដូច្នេះ ៖

យេ កេចិ បព្វជិតុកាមា តេ ឥមេ គណ្ហន្តុ ។ រីជនឯណានីមួយ មានប្រាថ្នានឹងបួសនៅឰដ៏ឋាននេះ សូមឲ្យជនអស់នោះ គប្បី

Websites: WatKhemaraRatanaram.org or WatKhmers.org

ទទួលយកទីឋានអស់នេះចុះ ។ រួចព្រះវិស្សុកម្មទេវបុត្រ ក៏ដេញបង្អើលអស់ខ្មោចបិសាច នូវម្រឹគបក្សីសាហាវទ្រើសឃ្នង គួរគប្បីស្បើម គួរគប្បីខ្ពើមខ្លាច ក៏បណ្ដេញឱ្យទៅនៅនាព្រៃឆ្ងាយអំពីព្រះបរមសាលាព្រះមហាបុរសរ័ត្ននោះហោង ។

សោ វិស្សុកម្មោ សក្កដ្ឋានមេវ គតោ ។ បពិត្រអើយ រីព្រះវិស្សុកម្មទេវបុត្រ ប្រដាប់ស្រេចនូវប្រការអម្បាលនោះហើយ ហោះផ្សងទៅកាន់សួគ៌ទេពលោកនាយ ដ៏ជាឋានពិមាននៃអាត្មាវិញហោង ។

មហាសត្តោបិ ឯកបទិកមគ្គំ ទិស្វា បព្វជិតានំ វសនដ្ឋានំ ភវិស្សតីតិ សល្លក្ខេត្វា ។ បពិត្រអើយ ព្វដ៏កាលនោះ រីព្រះមហាសត្វស្ដេចយល់ផ្លូវចុះតែជើងអ្នកមួយ ដើរចូលទៅនោះហើយ ព្រះអង្គគិតថា ‹‹ឱ! ឋាននេះអើយ គួរតែជាលំនៅនៃអ្នកបួសពិតប្រាកដ›› ។ ព្រះមហាក្សត្រទ្រង់រំពឹងពិចារណានូវប្រការអម្បាលនោះហើយ ព្រះអង្គទុកសម្ដេចព្រះរាជមទ្រីទេពី នូវព្រះរាជបុត្រទាំងពីរ នៅព្វដ៏ទ្វារអាស្រមបទនោះ ហើយស្ដេចចូលទៅតែមួយព្រះអង្គឯង ទ្រង់រមិល

មើលយល់អក្សរ នៅឰដ៏ខ្លោងទ្វារព្រះបរមសាលានោះកូវ ស្ដេចទ្រង់ព្រះចិន្ដាពិចារណាថា ឱឋាននេះហើយ មិនអង្គឹអ្នកឯណាឡើយ គឺព្រះឥន្ទ្រាធិរាជឯង លោកមករណ្ដាប់ឲ្យជាឋានលំនៅអ្នកបួសហោង។ ស្ដេចទ្រង់ព្រះចិន្ដាដូច្នោះហើយ ក៏បើកទ្វារព្រះបរមសាលា ចូលទៅដាក់ព្រះខ័ននិងបំពង់ យកព្រះកៅទណ្ឌអំពីព្រះអង្សា ចេញហើយស្ដេចផ្លាស់សំពត់បរិសុទ្ធនោះចេញ ស្ដេចយកសំពត់ជ្រលក់អម្ពត់នោះមកទ្រង់ស្រេចហើយ ព្រះអង្គយកស្បែកខ្លាទាំងក្រចក មកស្ពាយឆៀងឰដ៏ស្មាឆ្វេង ហើយចងព្រះកេសាជដាមណ្ឌល ជាមហាឥសីទ្រង់ឈើច្រតឫសីក្រហមល្អបីដូចផ្លែញៅទុំ ហើយស្ដេចចេញពីក្នុងបរមសាលា មកគង់នៅនាថ្មដា ឰដ៏ទ្វារបរមសាលានោះ ស្ដេចមានសេចក្ដីបីតិត្រេកអរថា អហោ ឱដូចអញគិតនេះហើយ រីផ្នួសអញនេះ បរិបូណ៌ក្សេមប្រសើរពេកណាស់ ។ ក្សិណនោះ ស្ដេចឡើងលើឋានចង្ក្រមណ៍ ហើយស្ដេចដើរចង្ក្រមទៅទៀបព្រះរាជបុត្រ ព្រះរាជទេពីយល់ល្អដូចព្រះបច្ចេកពោធិប្រពៃពេកហោង ។

មន្ទី ទេវិចិ ឱសោកេាន្ដិ សញ្ញាជិត្វា មហាសត្តស្ស

Websites: WatKhemaraRatanaram.org or WatKhmers.org

ចាទេសុ និបតិត្វា ។ បពិត្រអយ ឮដ៏កាលនោះ សម្ដេចព្រះភគវតី ព្រះនាងមទ្រី ដ៏ជាក្សត្រិយ៍មានលក្ខណាប្រពៃ ព្រះនាងរមិលមើលទៅ យល់ព្រះមហាក្សត្រហើយ ព្រះនាងទ្រង់ព្រះកន្សែងសោកា ហើយចូលទៅក្រាប នៅក្រោមព្រះបាទព្រះមហាក្សត្រ ហើយព្រះនាងបណ្ដើរព្រះរាជបុត្រទាំងពីរ ទៅនៅនាព្រះបរមសាលា ដ៏សមគួរនឹងអាត្មា ទើបព្រះនាងទ្រង់នូវសំពត់សំបកឈើ គិតដ៏អ្នកក្រងនីទៅនូវស្បូវភ្លាំង ស្ពាយឆៀងនូវស្បែកខ្លាទាំងក្រចក ក្រវាត់ស្បូវភ្លាំងជាវត្ថពន្ធ ហើយនាងចងព្រះកេសាជដាមណ្ឌល តម្កល់ជាឫសីបរិបូណ៌ស្រេចហើយ ទើបបំបួសរាជកុមារទាំងពីរ ជាតាបសកុមារឯក្រោយហោង ។

ចត្តារោ ខត្តិយា វង្កតបព្វតកុច្ឆិយំ វសឹសុ ។ វីក្សត្រទាំង ៤ ព្រះអង្គ ស្ដេចយាងទៅសាងព្រះផ្នួសបួសជាតាបសឫសី នៅនាព្រៃភ្នំគិរីវង្កតបព៌ត ។ អណ្ដាប់នោះ ព្រះនាងមទ្រីទេវី ក្រាបទូលសូមបម្រើព្រះមហាក្សត្រថាដូច្នេះ «បពិត្រព្រះមហាឫសីអើយ ចាប់ដើមតាំងពីថ្ងៃនេះទៅ កុំបីព្រួយព្រះរាជហឫទ័យ ទៅព្រៃស្វែងរកផ្លែឈើមើមឈើ

Websites: WatKhemaraRatanaram.org or WatKhmers.org

នោះឡើយ ចូរអម្ចាស់បន្លែងក្មេងទាំងពីរនៅនាអាស្រមបទចុះ ផានា លើខ្លួនខ្ញុំអម្ចាស់ឯង នឹងដើរទៅស្វែងរកផ្លែឈើមើមឈើ នាំមកចិញ្ចឹម អ្នកទាំង ៣ នៅឰដ៏អាស្រមបទនេះហោង›› ។ ឰដ៏កាលនោះ ព្រះ មហាក្សត្រព្រះអង្គបន្ទូលនូវក្រិត្យផ្ទួសនឹងព្រះនាងមទ្រីវិញថា ‹‹ហៃ នាងអើយ ចាប់ដើមពីថ្ងៃនេះទៅ ថាបើពុំជួកាលកុំអាលមកកាន់អញ ណា ត្បិតយើងទាំងពីរនេះ បានបួសជាមហាឫសីហើយ, នាងអើយ! នាបីហៅថាស្ត្រីទាំងឡាយនោះ រមែងតែងនឹងជាមន្ទិលនៃអ្នកបួស ក្តាត់ហោង ។ នាងអើយ ចាប់ដើមតាំងពីថ្ងៃនេះទៅ ថាបើពុំជួកាលកុំ អាលនាងមកកាន់អញឡើយ ។ ក្សិណនោះ សម្តេចព្រះរាជមទ្រី ទទួលយកព្រះបន្ទូលថា សាធុៗ ពីរោះពេកហោង ។

មហាសត្តស្ស មេត្តានុភាវេន សមន្តា តិយោជនម្ហិ សព្វេ តិរច្ឆានាបិ អញ្ញមញ្ញំ មេត្តចិត្តំ បដិលភឹសុ ។ ឰដ៏កាលនោះ ព្រះមហាសត្វព្រះអង្គសឹងសូត្រមន្តចំរើនមេត្តាភាវនា នៅនាព្រៃនោះ កាលឯណាមិញ រីអស់សត្វតិរច្ឆានផងទាំងឡាយអម្បាលម៉ាន ពីដើម នោះរែងតែងនឹងបៀតបៀនគ្នា ក៏ប្រែខ្វៃជាមិត្រមេត្រីទៅមកកាន់គ្នា

Websites: WatKhemaraRatanaram.org or WatKhmers.org

វិញ ។ បពិត្រអើយ រីអស់សត្វតិរច្ឆានទាំងឡាយ នៅព្រៃដ៏ឋានជុំវិញមានចម្ងាយនោះបីយោជន៍ ហេតុតែដោយនូវអានុភាពព្រះមហាក្សត្រចំរើនមេត្តាភាវនា អស់ម្រឹគាសឹងតែបណ្តាលជាមេត្រីនឹងគ្នាទៅវិញទៅមកហោង ។

មទ្ទី ទេវី ចាតោវ វុដ្ឋាយ ចាដីយំ បរិភោជនីយំ ឧបដ្ឋបេត្វា ។ បពិត្រអើយ រីនឹងស្រដីឯក្រឹត្យសម្តេចព្រះភគវតី ព្រះនាងមទ្រី បម្រើព្រះបរមពោធិសត្វនោះ នាកាលព្រឹកព្រហាមអរុណោទ័យថ្ងៃរះឡើង ព្រះនាងដោះឡើងទៅបោសអាស្រមបទ ហើយដងទឹកស្រង់ ទឹកឆាន់ លើកទឹកស្ងួន់ទៅប្រគេន ព្រះមហាក្សត្រស្រេចហើយ ទើបព្រះនាងក្រឡាប់វិលមកប្រវាឱបក្រសោបព្រះរាជបុត្រទាំងពីរនោះថើប ហើយផ្តាំថា តាត បិយបុត្តកា ថាហៃកូនស្ងួនសម្លាញ់ម្តាយទាំងពីរអើយ កុំបាប្រហែសធ្វេសទៅលេងឆ្ងាយ ពីព្រះជនកបាឡើយ ព្រះនាងផ្តាំដូច្នោះហើយ ក៏ទ្រង់ពនាងក្រស្នាបណ្តើរបាជាលីនាំទៅផ្ញើនឹងព្រះមហាក្សត្រ ហើយទូលថា «បពិត្រព្រះរាជឫសីអើយ កុំបីព្រះអង្គប្រហែសព្រះរាជបុត្រទាំងពីរឡើយ កុំឲ្យទៅលេងឆ្ងាយពី

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះបាទព្រះអង្គឡើយ›› ។ ព្រះនាងទូលផ្ដាំព្រះមហាក្សត្រស្រេចហើយ ព្រះនាងយកកញ្ជើ សង្រែកដងវែក ដាក់លើព្រះអង្សា ព្រះហស្តប្រវា កាន់ទំពក់និងជ្រនីក ម្នីម្នាទៅក្នុងកម្លុងព្រៃ ស្វែងរកផ្លែឈើមើមឈើ បានពេញកញ្ជើ នាំមកដាក់នៅអាស្រមបទនោះស្រេចហើយ ទើប ព្រះនាងពព្រះរាជបុត្រទាំងពីរ ទៅផ្ងូតទឹកជូតពពឹកភ្នែកស្រេចហើយ ព្រះនាងពឡើងមកហោង ។ បពិត្រអើយ រីក្សត្រទាំង ៤ អង្គសឹង ទៅជំនុំគ្នា នាព្រះបរមសាលា ហើយក៏សោយនូវផ្លែឈើ មើមឈើ ទំខ្ទីនោះហោង ។

តតោ មទ្ទី ទេ្វ បុត្តេ គហេត្វា អត្តនោ បណ្ណសាលំ គច្ឆតិ ។ បពិត្រអើយ រីក្សត្រទាំង ៤ អង្គ ទ្រង់សោយស្រេចហើយ ទើបព្រះនាងបណ្ដើរព្រះរាជបុត្រទាំងពីរ ទៅសឹងឯបរមសាលាព្រះ នាងវិញ ។

ឥមិនាវ និយាមេន តេបិ ចត្តារោ ខត្តិយា វង្កតបព្វតកុច្ឆិម្ហិ សត្ត មាសេ វសឹសុ ។ បពិត្រអើយ រីក្សត្រទាំង ៤ ព្រះអង្គនោះ ទៅសឹងនៅឰដ៏ភ្នំគិរីវង្កតបព៌តនោះ កំណត់ ៧ ខែ

ដោយនូវដំណើរនិទានដែលយើងបានស្រដីមកនេះឯង ។

វេឡុវេសេនគាណ្ឌំ និដ្ឋិតំ ។ បពិត្រអើយ អាត្មាភាពសម្ដែងថ្លែងព្រះធម៌វិសេសទេសនា ព្រះមហាជាតក កណ្ឌវេនប្បវេសន៍ ដ៏ប្រដាប់នូវព្រះគាថា ៥៧ ព្រះគាថា ក៏ចប់បរិបូណ៌ដោយសមគួរនៅវេលានេះឯងហោង ៕៚

(ចប់កណ្ឌវេនប្បវេសន៍ ទី ៤ តែប៉ុណ្ណេះ)

Websites: WatKhemaraRatanaram.org or WatKhmers.org

វាយខំព្យូទ័រសាឡើងវិញ

ដោយ

**លោកគ្រូអាចារ្យ ឈឹម សំបូរ**

និង

ត្រួតពិនិត្យកែសម្រួលអក្ខរាវិរុទ្ធ

ដោយ

លោកគ្រូ **ធម្មនាថ ផនប្រសិទ្ធិ៍**

ដើម្បីផ្សព្វផ្សាយ ជូនជាធម្មទាន តាមរិបសាយ

សព្វទានំ ធម្មទានំ ជិនាតិ ធម្មទានឈ្នះអស់ទានទាំងពួង

Websites: WatKhemaraRatanaram.org or WatKhmers.org